# កំណត់ត្រាសង្ខេប ៖ ការផ្លាស់ទីលំនៅក្នុងអំឡុងពេលមានជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងសិទ្ធិមានលំនៅឋាន និងទីជម្រកសមរម្យ

## សេចក្តីផ្តើម ៖

លទ្ធផលនៃជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលអូសបន្លាយពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដាឆ្នាំ២០២៥ បានប៉ះពាល់ដល់ប្រជាជនរាប់សែននាក់ដែលត្រូវភៀសខ្លួនឆ្លងកាត់ខេត្តចំនួន៥ គឺខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ព្រះវិហារ ពោធិ៍សាត់ និងសៀមរាប។ យោងតាមតួលេខដែលចេញផ្សាយដោយក្រសួងការពារជាតិ គិតត្រឹមថ្ងៃទី ៣១ ខែកក្កដា បានបង្ហាញថា មានប្រជាជនប្រមាណ ១៧២.០៩៤ នាក់ត្រូវបានផ្លាស់ទីលំនៅ។ ក្រោយកិច្ចព្រមព្រៀងឈប់បាញ់រវាងប្រទេសទាំងពីរកាលពីថ្ងៃទី២៨ ខែកក្កដា ប្រជាជនមួយចំនួនបានចាប់ផ្តើមវិលត្រឡប់ទៅលំនៅឋានវិញ ។ យ៉ាងណាក៏ដោយ នៅពាក់កណ្តាលខែសីហា មានការប៉ាន់ប្រមាណថា មានប្រជាជនរាប់ម៉ឺននាក់នៅកំពុងភៀសខ្លួននៅឡើយ។ ទោះបីជាមានបទឈប់បាញ់ក៏ដោយ ក៏ភាពតានតឹងនៅតាមបណ្តោយព្រំដែនបានបន្តកើតមាន ហើយមានពាក្យចចាមអារ៉ាមជាច្រើន ដែលបង្កឱ្យមានការភ័យខ្លាចនៃការបន្តបាញ់កាំភ្លើងធំផ្លោងដាក់គ្នា ដូចនេះការផ្លាស់ទីលំនៅក៏នៅតែមានបន្តទៀត។

ខេត្តដែលរងគ្រោះខ្លាំងបំផុតដោយជម្លោះព្រំដែននោះ ក៏ជាខេត្តដែលមានវិវាទដីធ្លី និងជាទូទៅប្រជាជននៅទីនោះពឹងផ្អែកទៅលើធនធានធម្មជាតិ។ ដីធ្លីនិងធនធានធម្មជាតិនៅទីនោះក៏ជាមូលដ្ឋានរបស់សហគមន៍ជនជាតិដើមភាគតិច ដែលជាក្រុមរងផលប៉ះពាល់ជាពិសេសដោយជម្លោះដីធ្លី។ បរិបទនេះរួមចំណែកដល់ភាពតានតឹងជាច្រើននៃអ្នកផ្លាស់ទីលំនៅ និងការសម្រេចចិត្តរបស់ពួកគេក្នុងការត្រឡប់ទៅលំនៅឋានរបស់ពួកគេវិញ។

នៅក្នុងកំណត់ត្រាសង្ខេបនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») លើកឡើងពីបញ្ហាប្រឈមរបស់អ្នកផ្លាស់ទីលំនៅដោយសារជម្លោះព្រំដែន ដែលចែករំលែកទស្សនៈខ្លះៗ អំពីបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិមានលំនៅឋាន ការផ្លាស់ទីលំនៅ និងជម្លោះ និងផ្នែកចុងបញ្ចប់នៃកំណត់ត្រាសង្ខេបនេះ គឺជាអនុសាសន៍ផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ។



## ស្ថានភាពក្នុងអំឡុងពេលផ្លាស់ទីលំនៅ ៖

ក្នុងរយៈពេលប៉ុន្មានថ្ងៃ និងសប្តាហ៍ មុនឈានដល់ថ្ងៃទី២៤ ខែកក្កដា ប្រជាជនជាច្រើននៅក្នុងខេត្តជាប់ព្រំដែនបានចាប់ផ្តើមចាកចេញពីលំនៅឋានរបស់ពួកគេ ដោយបានគិតថាភាពតានតឹងនឹងមានការកើនឡើងនៅតាមព្រំដែន។ ប្រជាជនជាច្រើនបានស្វែងរកទីជម្រកនៅជំរំជនភៀសសឹក ដែលភាគច្រើនត្រូវបានសាងសង់នៅតាមវត្តអារាម សាលារៀន និងទីជម្រកបណ្តោះអាសន្ន។ យោងតាមក្រសួងការពារជាតិ ចំនួនជនភៀសសឹកក្នុងដំណាច់ខែកក្កដា មានចំនួន ១៧២.០៩៤ នាក់។ ក្នុងអំឡុងខែសីហា បុគ្គលម្នាក់ៗ និងក្រុមគ្រួសារដែលបានផ្លាស់ទីលំនៅ បានចាប់ផ្តើមត្រឡប់ទៅលំនៅឋានរបស់ពួកគេវិញ។ ទោះជាយ៉ាងណា យោងតាមការប៉ាន់ប្រមាណមួយចំនួន គិតត្រឹមពាក់កណ្តាលខែសីហា មានប្រជាជនប្រមាណ ៣០.០០០នាក់ កំពុងបន្តផ្លាស់ទីលំនៅ។ អ្នកដែលត្រឡប់មកវិញបានលើកឡើងពីភាពចាំបាច់ខាងសេដ្ឋកិច្ច ពោលគឺពុំមានលទ្ធភាពរកប្រាក់ចំណូលក្នុងជំរំភៀសសឹក និងការសងបំណុលផងដែរ។ ជាលទ្ធផលនៃការបាញ់ផ្លោងជាថ្មីនៅចុងខែកញ្ញានេះ បណ្តាលឱ្យប្រជាជនរាប់រយគ្រួសារនៅខេត្តព្រះវិហារបានចាកចេញពីលំនៅឋានទៅជំរំភៀសសឹកជាថ្មីទៀត។

## បទពិសោធន៍ និងការព្រួយបារម្ភរបស់អ្នកផ្លាស់ទីលំនៅ ៖

ម.ស.ម.ក បានទទួលព័ត៌មានពីប្រជាជនមួយចំនួន រួមទាំងជនជាតិដើមភាគតិច ដែលត្រូវបានបញ្ជាឱ្យចាកចេញពីលំនៅឋានរៀងៗខ្លួននៅក្នុងខេត្តព្រះវិហារ ពោធិ៍សាត់ និងឧត្តរមានជ័យ។ ក្នុងករណីខ្លះ អាជ្ញាធរដែលបញ្ជាឲ្យចាកចេញនោះ ភាគច្រើនជាមេឃុំ ប្រធានភូមិ ឬអាជ្ញាធរខេត្ត។ ខណៈពេលដែលប្រជាជនភាគច្រើនចាកចេញដោយស្ម័គ្រចិត្ត ប៉ុន្តែអ្នកផ្សេងទៀតមានការស្ទាក់ស្ទើរក្នុងការចាកចេញពីលំនៅឋានរបស់ពួកគេ ប៉ុន្តែត្រូវតែធ្វើតាមបញ្ជារបស់អាជ្ញាធរ។ ពួកគេត្រូវបានផ្លាស់ទីលំនៅក្នុងរយៈពេលខុសៗគ្នាចន្លោះពី ១៦ ទៅ ៤៥ ថ្ងៃ។ ក្នុងអំឡុងពេលចេញផ្សាយកំណត់ត្រាសង្ខេបនេះ ពួកគេមួយចំនួនបានត្រឡប់មកលំនៅឋានរៀងៗខ្លួនវិញហើយ។

បន្ថែមលើការភ័យខ្លាច លំនៅឋានរបស់ពួកគេអាចនឹងត្រូវបានបំផ្លាញ ឬខូចខាតដោយសារគ្រាប់កាំភ្លើងធំក្នុងអំឡុងពេលជម្លោះ ឬរឹបអូសដោយយោធាថៃ មានការព្រួយបារម្ភមួយចំនួនទៀត ត្រូវបានចែករំលែក ហើយអ្នកទាំងអស់នោះបាននិយាយប្រាប់ ម.ស.ម.ក អំពីបទពិសោធន៍មួយចំនួនរបស់ពួកគេ ៖

- ភាគច្រើនអ្នកដែលបាននិយាយប្រាប់ ម.ស.ម.ក បានសម្តែងការភ័យព្រួយថា ពួកគេអាចនឹងបាត់បង់ដីធ្លី និងលំនៅឋានដោយសារ «ជនឆ្លៀតឱកាស» ឬ «អ្នកមានអំណាច» ដែលឆ្លៀតឱកាសដណ្តើមយកដី និងកាន់កាប់លំនៅឋានរបស់ពួកគេ ដែលបណ្តាលឱ្យពួកគេក្លាយជាអ្នកគ្មានដីធ្លីរស់នៅ។ មានការកត់សម្គាល់ថាអ្នកទាំងអស់ដែលបានលើកឡើងពីការព្រួយបារម្ភនេះក៏បានសម្តែងការភ័យព្រួយថាប្រសិនបើសេណារីយ៉ូនេះកើតឡើង ពួកគេនឹងមិនអាចទាមទារដីធ្លី និងលំនៅឋានរបស់ពួកគេបានមកវិញទេ ទោះបីជាការពិតអ្នកទាំងអស់នោះនឹងច្បាមយកដីធ្លី និងលំនៅឋានរបស់ពួកគេដោយខុសច្បាប់ក៏ដោយ។
- ក្នុងកំណត់ហេតុពាក់ព័ន្ធមួយចំនួន ក៏បានលើកឡើងពីការភ័យព្រួយដែរថា ដី និងលំនៅឋានរបស់ពួកគេនឹងត្រូវទាហានថៃរឹបអូសយកទៅឲ្យប្រជាជនថៃ។

- ពួកគេភាគច្រើនក៏បានសម្តែងការភ័យព្រួយអំពីទ្រព្យសម្បត្តិ ខណៈពេលដែលមានការផ្លាស់ទីលំនៅ រួមមានគោក្របី ផលិតផលកសិកម្ម ម៉ូតូ និងរបស់របរប្រើប្រាស់ក្នុងផ្ទះ។ មានអ្នកមួយចំនួនបាននិយាយថា តាមការមើលឃើញរបស់ពួកគេ អាជ្ញាធរបានការពារទ្រព្យសម្បត្តិរបស់ពួកគេបានយ៉ាងល្អ ប៉ុន្តែអ្នកមួយចំនួនទៀតដែលបានត្រឡប់មកលំនៅឋានវិញបានត្អូញត្អែរថា ទ្រព្យសម្បត្តិរបស់ពួកគាត់ត្រូវបានលួច។ ជនជាតិដើមភាគតិចខ្លះបានពោលថាគោក្របី និងម៉ូតូ បានបាត់មិនទាន់រកឃើញមកវិញទេ ខណៈអ្នកខ្លះទៀតរៀបរាប់ថា សម្ភារកសិកម្មមានតម្លៃ ២០ម៉ឺនរៀល ត្រូវបានលួច។
- ក្តីបារម្ភមួយទៀតដែលសហគមន៍ជនជាតិដើមភាគតិចលើកឡើងជាពិសេសនោះ គឺផលប៉ះពាល់នៃផ្សែងពុលសាយភាយមកពីសំបកផូស្វ័រពណ៌ស ដែលយោធាថៃបានប្រើប្រាស់ក្នុងអំឡុងពេលជម្លោះព្រំដែន ដោយផលប៉ះពាល់របស់វាទៅលើជីវភាព និងការរស់នៅបែបប្រពៃណីរបស់ពួកគេ។ កន្លងមក ពួកគេពឹងផ្អែកលើទឹកអូរធម្មជាតិប្រើប្រាស់ប្រចាំថ្ងៃតាមបែបប្រពៃណី ប៉ុន្តែបច្ចុប្បន្នពួកគេលែងប្រើប្រាស់ទឹកអូរនោះទៀតហើយ ដោយខ្លាចក្រែងមានគ្រោះថ្នាក់ដោយសារសារជាតិពុល។

ទោះបីជាប្រជាជនបានត្រឡប់មកលំនៅឋានរបស់ពួកគេវិញក៏ដោយ ក៏ពួកគាត់ទាំងនោះបានបង្ហាញអារម្មណ៍ភ័យខ្លាចជាបន្តបន្ទាប់ ហើយក្រុមគ្រួសាររបស់ពួកគេ និងអ្នកភូមិផ្សេងទៀតក៏មានអារម្មណ៍ស្រដៀងគ្នាដែរ។ បញ្ហាមួយគឺ អសមត្ថភាពក្នុងការរកប្រាក់ចំណូលអំឡុងពេលផ្លាស់ទីលំនៅគឺជាក្តីព្រួយបារម្ភមួយយ៉ាងសំខាន់ បារម្ភអំពីសុខភាព និងសុខុមាលភាពគ្រួសាររបស់ពួកគេ។ ប្រជាជនខ្លះទៀតបានសម្តែងការភ័យព្រួយថា ជម្លោះនឹងផ្ទុះឡើងជាថ្មីទៀតហើយកាន់តែយូរអង្វែង បណ្តាលឱ្យពួកគេបាត់បង់ដីធ្លី និងលំនៅឋាន។

## ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ៖

សិទ្ធិមានលំនៅឋានសមរម្យត្រូវបានធានាដោយមាត្រា១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.អ.ស.ស.ស.វ) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ក្នុងឆ្នាំ ១៩៩២។ កត្តាចាំបាច់ដែលជាកាតព្វកិច្ចរបស់រដ្ឋក្នុងការទប់ស្កាត់ការរំលោភសិទ្ធិលំនៅឋានត្រូវតែអនុវត្ត បើទោះជានៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធផ្ទៃក្នុងក៏ដោយ។[1]

ការបាត់បង់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិគំរាមកំហែងដល់ការទទួលបានសិទ្ធិមនុស្សមួយចំនួនដែលរដ្ឋមានកាតព្វកិច្ចគោរពការពារ និងបំពេញ ពោលគឺសិទ្ធិទទួលបានអាហារ សេរីភាពក្នុងការធ្វើដំណើរ និងការជ្រើសរើសលំនៅឋានដើម្បីការពារពីការជ្រៀតជ្រែកក្នុងភាពឯកជន និងលំនៅឋាន ទឹក និងអនាម័យ និង

[1] មហាសន្និបាតអង្គការសហប្រជាជាតិ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ ជាធាតុផ្សំនៃសិទ្ធិទទួលបានបទដ្ឋានរស់នៅសមរម្យ និងសិទ្ធិមិនរើសអើងក្នុងបរិបទនេះ Balakrishnan Rajagopal - សិទ្ធិទទួលបានលំនៅឋានសមរម្យអំឡុងពេលមានជម្លោះហិង្សា', អេ/៧៧/២៩០, (២០២២), ទ១៥។

សុខភាព។[2] ការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិក៏ជះឥទ្ធិពលដល់ជីវភាពរស់នៅ ធ្វើឲ្យមនុស្សជាច្រើនប្រឈមនឹងភាពក្រីក្រ ហើយប៉ះពាល់ដល់លទ្ធភាពទទួលបានអាហារ និងលំនៅឋានសមរម្យ។ ការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិក៏ជះឥទ្ធិពលដល់ជីវភាពរស់នៅ ធ្វើឲ្យមនុស្សជាច្រើនប្រឈមនឹងភាពក្រីក្រ ហើយប៉ះពាល់ដល់លទ្ធភាពទទួលបានអាហារ និងលំនៅឋានសមរម្យ។

ទោះបីលំនៅឋានមិនបានខូចខាតក៏ដោយ ជាបទពិសោធន៍ទូទៅ ម្ចាស់លំនៅឋានមានការពិបាកក្នុងការចូលទៅរស់នៅក្នុងលំនៅឋានរបស់ខ្លួនបានទៀតឡើយ ក្នុងខណៈដែលត្រូវបានជម្លៀសចេញពីលំនៅឋានរយៈពេលយូរ គឺដោយសារកើតមានអំពើហិង្សាផ្សេងៗ ការជីកយករ៉ែនៅនឹងផ្លូវចូល ឬយុទ្ធភណ្ឌមិនទាន់ផ្ទុះ ឬដីធ្លី និងលំនៅឋាននោះត្រូវបានដណ្តើមយកដោយអ្នកកាន់កាប់ថ្មី។[3] ជម្លោះក៏មាននិន្នាការឱ្យមានបញ្ហាជាប្រព័ន្ធដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើងក្នុងការកាន់កាប់លំនៅឋាន និងដីធ្លី។ ដូចដែលបានកត់សម្គាល់ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីលំនៅឋានក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ «សិទ្ធិទទួលបានលំនៅឋានសមរម្យអាចត្រូវបានរំលោភបំពានផងដែរតាមរយៈការិយាធិបតេយ្យ ការរំលោភសិទ្ធិក្នុងការវិលត្រឡប់មកវិញ ការអនុញ្ញាតឱ្យមានការរឹបអូសយកលំនៅឋាន [និង] ការរឹបអូស ឬការដកហូតលំនៅឋាន»។[4] លោកស្រីក៏បានកត់សម្គាល់ផងដែរ អំពីភាពងាយរងគ្រោះធ្ងន់ធ្ងរទាក់ទងនឹងសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លី ជាពិសេស គឺអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិច ដោយសារការមិនទទួលស្គាល់សិទ្ធិដីធ្លីតាមទំនៀមទម្លាប់បានធ្វើឱ្យមានការពិបាកសម្រាប់អ្នកដែលបានផ្លាស់ទីលំនៅដើម្បីបញ្ជាក់ពីសិទ្ធិកាន់កាប់ និងសិទ្ធិក្នុងស្តារជីវភាពឡើងវិញ និងទទួលបានសំណង។

មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ធានាសិទ្ធិទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ការរំលោភសិទ្ធិមនុស្សដែលត្រូវបានទទួលរង ដោយមិនគិតពីការរំលោភនោះត្រូវបានប្រព្រឹត្តដោយតួអង្គរដ្ឋ ឬតួអង្គមិនមែនរដ្ឋ។ ជាតុផ្សំមួយនៃមធ្យោបាយដោះស្រាយដ៏មានប្រសិទ្ធភាពគឺជុសជុលការខូចខាត ដែលអាចប្រើទម្រង់ជា «ការស្តារជីវភាពឡើងវិញ» គឺការប្រគល់ដល់ជនរងគ្រោះនូវទីតាំងដែលពួកគេធ្លាប់មានមុនពេលមានការរំលោភបំពាន ឬប្រសិនបើមិនអាចធ្វើទៅបានតាមមធ្យោបាយនេះទេ គឺត្រូវផ្តល់ជាសំណង។ ក្នុងន័យនេះ «ជនភៀសខ្លួនទាំងអស់មានសិទ្ធិស្តារលំនៅឋាន ដីធ្លី និង/ឬទ្រព្យសម្បត្តិដែលពួកគេត្រូវបានដកហូតតាមទំនើងចិត្ត ឬដោយខុសច្បាប់ ឬទទួលបានសំណងសម្រាប់លំនៅឋាន ដីធ្លី និង/ឬទ្រព្យសម្បត្តិទាំងអស់នោះដែលមិនអាចស្តារឡើងវិញបាន»។[5]

គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេសគឺជាបទដ្ឋានសិទ្ធិមនុស្សដ៏ចម្បងស្តីពីការផ្លាស់ទីលំនៅ និងកំណត់ឡើងវិញនូវកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងលំនៅឋាន ដីធ្លី ទ្រព្យសម្បត្តិ។ គោលការណ៍មួយចំនួនដែលអនុវត្តជាពិសេសចំពោះបរិបទបច្ចុប្បន្ននៅកម្ពុជាមានដូចខាងក្រោម ៖

- **គោលការណ៍ទី៧ ៖** មុននឹងសម្រេចចិត្តណាមួយដែលតម្រូវឱ្យមានការផ្លាស់ទីលំនៅ អាជ្ញាធរពាក់ព័ន្ធត្រូវធានាថាជម្រើសដែលអាចធ្វើទៅបានទាំងអស់ត្រូវបានពិនិត្យពិច័យយ៉ាងច្បាស់លាស់ ដើម្បីជៀស

[2] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, 'បញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងបរិបទនៃការផ្លាស់ទីលំនៅក្នុងប្រទេស - របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៃជនភៀសខ្លួនផ្ទៃក្នុង Cecilia Jimenez-Damary', អេ/អេហ្សអាស៊ី/៤៧/៣៧, (២០២១), §១៣។

[3] មហាសន្និបាតអង្គការសហប្រជាជាតិ (យូអិនជីអេ) អេ/៧៧/១៩០ §១៣។

[4] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង ៣ ខាងលើ, §៨។

[5] មហាសន្និបាតអង្គការសហប្រជាជាតិ (យូអិនជីអេ) អេ/៧៧/១៩០, §៧១។

រាំងការផ្លាស់ទីលំនៅទាំងអស់គ្នាពេក។ ប្រសិនបើគ្មានជម្រើសណាមួយទេ វិធានការទាំងអស់នឹងត្រូវធ្វើឡើងដើម្បីកាត់បន្ថយការផ្លាស់ទីលំនៅ និងផលប៉ះពាល់អវិជ្ជមាន។

- **គោលការណ៍ទី១៩ ៖** រដ្ឋស្ថិតនៅក្រោមកាតព្វកិច្ចពិសេសមួយក្នុងការការពារប្រឆាំងនឹងការផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិច ជនជាតិភាគតិច កសិករ អ្នកគង្វាល និងក្រុមផ្សេងទៀតដែលមានការពឹងផ្អែកពិសេស និងការផ្សារភ្ជាប់ទៅនឹងទឹកដីរបស់ពួកគេ។
- **គោលការណ៍ទី២៨ ៖** អាជ្ញាធរមានសមត្ថកិច្ចមានកាតព្វកិច្ច និងការទទួលខុសត្រូវចម្បងក្នុងការបង្កើតលក្ខខណ្ឌ ក៏ដូចជាផ្តល់មធ្យោបាយ ដែលអនុញ្ញាតឱ្យជនភៀសខ្លួនក្នុងស្រុកត្រឡប់ទៅលំនៅឋានវិញដោយស្ម័គ្រចិត្ត សុវត្ថិភាព និងដោយសេចក្តីថ្លៃថ្នូរ ឬតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្តនៅក្នុងផ្នែកផ្សេងទៀតនៃប្រទេស។
- **គោលការណ៍ទី២៩ ៖** អាជ្ញាធរមានសមត្ថកិច្ចមានកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការជួយប្រជាជនភៀសខ្លួនដែលត្រឡប់មកលំនៅឋានវិញ និង/ឬ តាំងទីលំនៅថ្មី ដើម្បីស្តារឡើងវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ចំពោះទ្រព្យសម្បត្តិ និងភោគៈដែលពួកគេបានបន្សល់ទុក ឬត្រូវបានដកហូតនៅពេលផ្លាស់ទីលំនៅ។ នៅពេលដែលមិនអាចយកមកវិញនូវទ្រព្យសម្បត្តិ និងភោគៈទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ ឬជួយជនទាំងនេះដើម្បីទទួលបានសំណងសមរម្យ ឬទម្រង់នៃសំណងសមរម្យផ្សេងទៀត។

## អនុសាសន៍ ៖

### ១. ម.ស.ម.ក សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាអនុវត្តអនុសាសន៍ដូចខាងក្រោម ៖

i. ធានា និងសម្រួលដល់ការវិលត្រឡប់ប្រកបដោយសុវត្ថិភាព និងស្ម័គ្រចិត្តរបស់ប្រជាជនដែលបានផ្លាស់ទីលំនៅក្នុងអំឡុងពេលមានជម្លោះមកកាន់លំនៅឋាន និងដីរបស់ពួកគេវិញ។

ii. សម្រាប់ប្រជាជនដែលមិនទាន់មានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការត្រឡប់ទៅលំនៅឋាន និងដីរបស់ពួកគេវិញ សូមធានាឱ្យមានលទ្ធភាពទទួលបានទីជម្រកសមរម្យ អាហារ និង ទឹកគ្រប់គ្រាន់ កន្លែងថែទាំសុខភាព និងអនាម័យ ខណៈដែលពួកគេកំពុងផ្លាស់ទីលំនៅនៅឡើយ។

iii. បង្កើតនីតិវិធីទាមទារសំណង និងសំណងសម្រាប់ប្រជាជនដែលទ្រព្យសម្បត្តិត្រូវបានខូចខាត ឬបំផ្លាញដោយសារជម្លោះ។ សូមប្រាកដថានីតិវិធីទាមទារសំណង និងសំណងបែបនេះអាចដំណើរការបាន ហើយត្រូវបានអនុវត្តដោយគ្មានការរើសអើង ដោយមានការយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថាស្ត្រី សហគមន៍ជនជាតិដើមភាគតិច ជនពិការ និងក្រុមជនងាយរងគ្រោះផ្សេងទៀតអាចពឹងពាក់បានពេញលេញទៅលើនីតិវិធីទាំងនេះ។

iv. ទប់ស្កាត់ការទន្ទ្រានយកដីដោយខុសច្បាប់ និងបើករណីនេះកើតឡើង ត្រូវធានាថាជនរងគ្រោះមានសិទ្ធិទទួលបានយុត្តិធម៌យ៉ាងឆាប់រហ័ស។

v. ធានាឱ្យមានការចេញផ្សាយទាន់ពេលវេលានូវតួលេខដែលបានធ្វើបច្ចុប្បន្នភាពអំពីអ្នកផ្លាស់ទីលំនៅ និងទីតាំងរបស់ពួកគេ ដោយសារព័ត៌មានទាំងនេះមិនត្រឹមតែជាផលប្រយោជន៍សាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏អាចអនុញ្ញាតឱ្យមានការសម្របសម្រួលបន្ថែមទៀតដើម្បីផ្តល់ជំនួយដល់អ្នកផ្លាស់ទីលំនៅទាំងនោះដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតផងដែរ។

**២. ម.ស.ម.ក សូមអំពាវនាវដល់ភាគីជម្លោះព្រំដែនទាំងពីរ រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ គោរពអធិបតេយ្យភាពរបស់ប្រទេសនីមួយៗ ដោយប្តេជ្ញាដោះស្រាយជម្លោះដោយសន្តិវិធី និងប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិដើម្បីធានាថា ការផ្លាស់ទីលំនៅបន្ថែមទៀត នឹងមិនកើតមានឡើងនៅក្នុងប្រទេសណាមួយឡើយ។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក **វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោង ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) (០) ១២ ៩៤១ ២០៦ ឬអ៊ីមែល vann.sophath@cchrcambodia.org។